# មេរៀនទី ៣៨៖ កំណើតរបស់អ៊ីសាក

## លោកុប្បត្តិ ២១៖១-៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/iS3M2jCF3Lg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/nRLZDOF-dtM

**គោលចំណង៖** ព្រះសន្យានាំនូវក្ដីអំណរឲ្យដល់យើង។

**ខគម្ពីរចងចាំ៖ ភីលីព ៤៖៤** *“ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង។”*

**ចំរៀង** ( *យូធូបលីង* )៖

១.ខ្ញុំសប្បាយរីករាយ https://youtu.be/2LWPsq-KZvo

២.បើអ្នកសប្បាយក្នុងព្រះយេស៊ូវ https://youtu.be/SsldqdQB-9U

៣. មានសុខសាន្តដូចទន្លេ https://youtu.be/BqKUDsWZq8s

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ធ្វើឲ្យសើច»




១. ចែកកុមារជាពីរក្រុមគឺក្រុម ក និងខ

២. ក្រុម ក នឹងជ្រើសរើសកុមារណាម្នាក់មកធ្វើជាអ្នកធ្វើកាយវិការ តែមិនត្រូវបញ្ចេញសម្លេងនោះទេ។ គ្រូត្រូវកំណត់នាទីក្នុងការធ្វើកាយវិការ ប្រសិនបើសមាជិកក្រុម ខ ណាម្នាក់សើច នោះក្រុម ក នឹងឈ្នះល្បែងនេះ។

៣. ប្រសិនបើក្រុម ខ មិនសើចទេ នោះក្រុម ក និងចាញ់ល្បែងនេះ។



៤. បន្តលេងល្បែងនេះ ដោយប្ដូរអ្នកធ្វើកាយវិការ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងអាចនឹងសើចសប្បាយបានពីព្រោះព្រះប្រទាន ក្ដីអំណរឲ្យដល់យើង។

### ៤. ការណែនាំមេរៀន

ពេលដែលមានមនុស្សឲ្យអំណោយមកអ្នក តើអ្នកមានអារម្មណ៍ដូចម្តេច? អ្នកមានអារម្មណ៍មានអំណរ? ជាគ្រីស្ទបរិសុទ្ធដែលមានជំនឿលើព្រះ មានហេតុផលជាច្រើនដើម្បីឲ្យយើងមានអំណរ។ ថ្ងៃនេះយើងនឹងរៀនអំពី លោក អ័ប្រាហាំ និង សារ៉ា ជាមនុស្សដែលមានពោរពេញដោយអំណរនៅពេលដែលព្រះបានប្រទានអំណោយដ៏វិសេសដល់ពួកគេ។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងព្រះគម្ពីររបស់យើងគឺនិយាយពី អ័ប្រាហាំ និងសារ៉ា។ ពួកគេបានរងចាំអស់ពេញមួយជីវិតរបស់គេដើម្បីមានកូនម្នាក់ ហើយព្រះបានសន្យាជាមួយអ័ប្រាហាំថា គាត់នឹងមានកូនមួយនៅពេលដែលគាត់មានអាយុ ៧៥ឆ្នាំ។ ប៉ុន្តែអស់ពេលជាច្រើនឆ្នាំកន្លងទៅ អ័ប្រាហាំ និង សារ៉ាមិនមានកូនទេ។ វាគឺជាការ

អាម៉ាស់មួយដែលពួកគេមិនអាចមានកូនបានក្នុងពេលនេះ ដូច្នេះយើងអាចមើលឃើញថា អ័ប្រាហាំ និង សារ៉ា ពិតជាចង់បានកូនខ្លាំងណាស់។ ប៉ុន្តែអ័ប្រាហាំមានជំនឿលើព្រះដែលទ្រង់តែងតែ រក្សាពាក្យសន្យារបស់ព្រះអង្គ។

ជាចុងក្រោយព្រះបានប្រទានកូនប្រុសដល់ សារ៉ា និងអ័ប្រាហាំ នៅពេលដែលសារ៉ាមានអាយុ៩០ឆ្នាំ ហើយអ័ប្រាហាំមានអាយុ ១០០ឆ្នាំ! តើអ្នកអាចស្រមើស្រម៉ៃមើលថាជីដូនចំណាស់អាយុ៩០ឆ្នាំអាច មានកូនបាន? រឿងនេះមើលទៅមិនអាចទៅរួចទេសំរាប់មនុស្ស ប៉ុន្តែព្រះគឺពេញដោយអំណាច ហើយព្រះអាចធ្វើឲ្យអ្វីៗដែលមិនអាចទៅរួចឲ្យទៅរួចបាន។

អ័ប្រាហាំ និង សារ៉ាសប្បាយចិត្តខ្លាំងណាស់។ នៅពេលចុងក្រោយកូនរបស់គាត់បានកើតមក ពួកគេមានអំណរខ្លាំងណាស់ដូច្នេះគាត់បានដាក់ឈ្មោះឲ្យកូនគាត់ថា អ៊ីសាក មានន័យថា "សំណើច" ហើយវាជាការ ល្អដែលមានអារម្មណ៍រីករាយ។ សេចក្តីសន្យារបស់ព្រះនាំមកនូវអំណរដល់យើង។

ព្រះបានប្រទានពរដល់យើងជាច្រើន ហើយព្រះពរនោះនាំមកនូវក្តីអំណរដល់យើង។ ព្រះបានប្រទានពរឲ្យយើងមានក្រុមគ្រួសារដែលស្រឡាញ់យើង ហើយអោបក្រសោបយើង។ ព្រះប្រទានអាហារដល់យើង។ ព្រះប្រទានពររូបកាយដ៏រឹងមាំដែលអាចរត់លេងបាន។ សប្តាហ៍នេះសូមចំណាយពេលយកចិត្តទុកដាក់ចំពោះអ្វីៗដែលធ្វើឲ្យយើងញញឹម និងធ្វើឲ្យយើងរីករាយ។ សូមចំណាយពេលក្នុងការអរព្រះគុណព្រះសំរាប់អ្វីៗ ដែលរីករាយ។ សូមចងចាំថា! ក្តីសន្យារបស់ព្រះនាំមកនូវក្តីអំណរ!

## ៦. សំនួរពិភាក្សា

១. ឈ្មោះ អ៊ីសាក មានអត្ថន័យដូចម្តេច? *(សំណើច)*

២. ហេតុអ្វីបានជាអ័ប្រាហាំ និង សារ៉ា ដាក់ឈ្មោះកូនគាត់ថា អ៊ីសាក?
*(ពីព្រោះព្រះបានប្រទានពរ ក្តីអំណរដល់ពួកគេតាមរយៈការប្រទានកូនឲ្យដល់ពួកគេ)*

៣. តើអ្វីជាអំណរសំរាប់អ្នកក្នុងសប្តាហ៍នេះ? *(សូមឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត "អធិស្ឋាន" "រាំ និងច្រៀងម្តើងព្រះ" "អរព្រះគុណ" ឬក៏ "សើច"

សម្ភារៈដែលត្រូវការ៖ ក្រដាស A4 ៤សន្លឹក ដែលសរសេរពាក្យថា "អធិស្ឋាន" "រាំ និងច្រៀងសរសើរតម្កើងព្រះ" "អរគុណព្រះ" "សើច" និងតុ




១. គ្រូត្រូវបិតក្រដាសទាំង៤ សន្លឹកនៅលើជញ្ជាំង ត្រង់ទីតាំងខុសៗគ្នា (មិនឲ្យកុមារឃើញពាក្យខាងក្នុងទេ)។

២. កុមារត្រូវរាំនៅជុំវិញតុ (ឬកៅអី) ដោយចាក់ភ្លេង ហើយនៅពេលភ្លេងឈប់កុមារត្រូវរត់ទៅកាន់ជញ្ជាំង ដែលគេបានជ្រើសរើសនោះ។




៣. កុមារត្រូវតែធ្វើតាមពាក្យដែលបានបិតនោះ។ ឧទាហរណ៍៖ ប្រសិន បើគេរត់ទៅរកជញ្ជាំងដែលបិតពាក្យថា "អធិស្ឋាន" ពួកគេត្រូវអធិស្ឋាន។ ហើយប្រសិនបើពួកគេរត់ទៅរកជញ្ជាំងដែលមានពាក្យថា"រាំ ច្រៀងសរសើរតម្កើងព្រះ" ពួកគេត្រូវរាំ។

៤. ឲ្យពេលកុមារ ១ នាទី ហើយបន្តលេងល្បែងនោះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះតែងតែចង់ឲ្យយើងមានអំណរ។ ព្រះប្រទានពរឲ្យយើងនូវអំណរ ដូច្នេះហើយយើងនឹងអាចអរសប្បាយ។ សូមយកចិត្តទុកដាក់ឲ្យប្រាកដជាមួយអ្វីល្អៗដែលព្រះ បានធ្វើសំរាប់យើង ដូច្នេះហើយយើងអាចនឹងមានអំណរ!

## ៨. ខគម្ពីរចងចាំ

**ភីលីព ៤៖៤** *"ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្ដងទៀតថា ចូរអរ សប្បាយឡើង។"*

## ៩. ហត្ថកម្ម **«ព្រះប្រទានអំណរដល់យើង»**



សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាស់ហត្ថកម្ម កូល័រផាត់ព៌ណ កន្ត្រៃ និងការបិត

១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយឲ្យកុមារផាត់ពណ៌ក្រដាស ហត្ថកម្មនោះ។

២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញមក។ បន្ទាប់មកកាត់រូបទារក ហើយបិតរូបនោះ នៅក្នុងកូនអង្រឹង។

៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវអំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរជានិច្ច!

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព័ន្ធកិច្ចរបស់ព្រះគឺម៉ត់ចត់ ប៉ុន្តែព្រះអង្គជ្រាបដឹងថាតើត្រូវមានអំណរដោយរបៀបណាផងដែរ។ រំលឹកឡើងវិញពីអំណោយមួយចំនួនដែលព្រះបានប្រទានមកដល់យើង។ តើអំណោយទាំងនោះនាំក្ដីអំណរដល់អ្នកដូចម្ដេចខ្លះ? ប្រហែលជាអំណោយទាំងនោះបានឆ្លើយតបទៅនឹងការអធិស្ឋានរបស់អ្នក ឬអ្វីដែលអ្នកមិនដែលបានទូលសូមពីព្រះសោះ។ ព្រះពេញចិត្តនឹងប្រទានអំណោយដែលនឹងពង្រឹង ហើយលើកទឹកចិត្តតាមវិធីជាច្រើន។ សូមសរសេរអំណោយទាំងនោះ ហើយអធិស្ឋានដោយអំណរ និងរក្សាអំណោយទាំងនោះនៅទីណាដែលនឹងរំលឹកយើងពីក្ដីអំណរនៃអំណោយរបស់ព្រះ។

## ព្រះប្រទានពរអំណរដល់យើង!

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម
កូល័រ កន្ត្រៃ និងការបិត
១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយ
ឲ្យកុមារផាត់ពណ៌ក្រដាសហត្ថកម្មនោះ រួមទាំងរូប
ទារក
២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញ
មក។ បន្ទាប់មកកាត់រូបកូនទារក ហើយបិតរូបនោះ
នៅក្នុងកូនអង្រឹង។
៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវ
អំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរ
ជានិច្ច។



## ព្រះប្រទានពរអំណរដល់យើង!

សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម
កូល័រ កន្ត្រៃ និងការបិត
១. ចែកក្រដាសហត្ថកម្មឲ្យកុមារម្នាក់១សន្លឹក ហើយ
ឲ្យកុមារផាត់ពណ៌ក្រដាសហត្ថកម្មនោះ រួមទាំងរូប
ទារក
២. កាត់ប្រអប់ដែលមានរូបអ័ប្រាហាំ និងសារ៉ាចេញ
មក។ បន្ទាប់មកកាត់រូបកូនទារក ហើយបិតរូបនោះ
នៅក្នុងកូនអង្រឹង។
៣. សូមចាំថា ព្រះតែងតែប្រទានពរដល់យើងនូវ
អំណោយល្អៗ ដូច្នេះហើយយើងអាចនឹងមានអំណរ
ជានិច្ច។

